**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣ . សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ដើម្បីធ្វើការសម្របសម្រួលជាមួយធនាគារឥណទានស្វីស ក្នុងការផ្តល់ស្ថិតិ និងព័ត៌មានផ្សេងៗជូនភ្នាក់ងារកម្រិតថ្នាក់ ដើម្បីធ្វើការវាយតម្លៃលើបរិស្ថានវិនិយោគ និងលើស្ថានភាពជារួមនៃប្រទេសកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១ :** បង្កើតគណៈកម្មការ ដើម្បីធ្វើការសម្របសម្រួល និងផ្តល់ទិន្នន័យពាក់ព័ន្ធនយោបាយ និងសេដ្ឋកិច្ច-សង្គម ដើម្បីផ្តល់ជូនទីភ្នាក់ងារកម្រិតថ្នាក់ សម្រាប់ធ្វើជាមូលដ្ឋានក្នុងកម្រិតថ្នាក់ប្រទេសកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សេង លឹមនៅ** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ហង់ជួន ណារ៉ុន** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម | **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការ ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៥- ឯកឧត្តម | **ជា វ៉ាន់ដេត** | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៦- ឯកឧត្តម | ម៉ៅ ថូរ៉ា | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- ឯកឧត្តម | ហ៊ូ តាំងអេង | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៨- ឯកឧត្តម | សក់ សេដ្ឋា | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- លោក | ឡូញ ហៃ | អគ្គនាយករង ធនាគារជាតិនៃកម្ពុជា | សមាជិក |

**ប្រការ ២ :** គណៈកម្មការ មានភារកិច្ចប្រមូលទិន្នន័យពាក់ព័ន្ធនយោបាយ និងសេដ្ឋកិច្ច-សង្គម ដើម្បីផ្តល់ជូនភ្នាក់ងារកម្រិតថ្នាក់ តាមរយៈធនាគារឥណទានស្ទីសហ្វីសបុសតុន។ គណៈកម្មការនេះ អាចមានក្រុមការងារមួយ សម្រាប់ជាជំនួយការក្នុងការប្រមូលទិន្នន័យ និងការងារពាក់ព័ន្ធផ្សេងៗ។

**ប្រការ ៣ :** គណៈកម្មការ មានភារកិច្ចសហការជាមួយធនាគារឥណទានស្វីស និងពិភាក្សាលើលទ្ធផលនៃការវាយតម្លៃ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទេសាភិបាលធនាគាជាតិនៃកម្ពុជា និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៤*
- *ឯកសារ-កាលប្បវត្តិ* ✓